ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការលើកពេលសវនាការ

***សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ*** មានកិត្តិយសសូមជម្រាបជូន លោក លោកស្រីមេធាវី ភាគីពាក់ព័ន្ធក្នុងសំណុំរឿង និងសាធារណជនមេត្តាជ្រាបថា ដោយសារស្ថានភាពនៃការចម្លងជំងឺកូវីដ-១៩ ក្នុង «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**» មានការរីករាលដាលឆាប់រហ័ស និងស្មុគស្មាញជាងព្រឹត្តិការណ៍សហគមន៍មុនៗ ហើយដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលក្នុងសហគមន៍បន្ថែមទៀត សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សម្រេច «**លើកពេលសវនាការ**» ដែលបានគ្រោងទុកនៅចន្លោះពេលពី **ថ្ងៃទី២៤ ខែកុម្ភៈ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១** ទៅពេលក្រោយវិញ។ សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ នឹងកំណត់កម្មវិធីសវនាការឡើងវិញក្រោយពីស្ថានភាពជំងឺកូវីដ-១៩ ក្នុង «**ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ**» បានធូរស្រាល។ ដោយឡែកពាក់ព័ន្ធនឹងសំណុំរឿងចាំបាច់មួយចំនួន លោក លោកស្រីចៅក្រមពិនិត្យ និងចាត់ការតាមការជាក់ស្តែង យោងតាមករណីនីមួយៗ ដោយគោរពតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល និងកាត់បន្ថយការប្រមូលផ្តុំ។

ចំពោះការបំពេញការងាររដ្ឋបាលប្រចាំថ្ងៃ និងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ នៅដំណើរការជាធម្មតា ប៉ុន្តែសូមថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់ត្រូវបំពេញភារកិច្ចរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវវិធានការអនាម័យ ពាក់ម៉ាស លាងដៃ រក្សាគម្លាត ចៀសវាងការប្រមូលផ្តុំ និងតាមដានសុខភាពជាប្រចាំ។

អាស្រ័យហេតុនេះ សូមលោក លោកស្រីមេធាវី ភាគីពាក់ព័ន្ធក្នុងសំណុំរឿង និងសាធារណជនមេត្តាជ្រាបជាព័ត៌មានតាមការគួរ។

*ថ្ងៃអង្គារ ១២កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១*

**លេខាធិការដ្ឋានរដ្ឋបាល**

អាសយដ្ឋានៈ អាគារលេខ ២៥, ២៦ និង ២៧ ផ្លូវលេខ ២១៧ សង្កាត់វាលវង់ ខណ្ឌ ៧ មករា, ភ្នំពេញ ទូរសារ-ទូរស័ព្ទ: (៨៥៥)-២៣ ៨៨ ៥០ ៨០
Adress: #25, 26 and 27, Street 217, Sangkat Vealvong, Khan 7makara, Phnom Penh, Cambodia. Fax-Phone : (855) - 23 88 50 80